Washington State
Department of Social & Health Services
DDA Developmental Disabilities Administration

# កម្មវិធីវាយតម្លៃ របស់ Developmental Disabilities Administration

## ពត៌មានស្តីពីសេវាកម្ម និងកម្មវិធីឧបត្ថម្ភសម្រាប់ប្រជាពលរដ្ឋ ដែលមានពិការភាពពីកំណើតឬពីក្មេងវ័យ

### សេចក្តីណែនាំអំពីកម្មវិធីវាយតម្លៃ DDA ៖

កម្មវិធីវាយតម្លៃ DDA (DDA Assessment) ត្រូវបានបង្កើតឡើង ដើម្បីវាស់ស្ទង់មើលអំពីតម្រូវការសេវាឧបត្ថម្ភរបស់ប្រជាពលរដ្ឋម្នាក់ៗ ដែលទទួលកម្មវិធីវាយតម្លៃនេះ។

កម្មវិធី DDA ជួយនាយកគ្រប់គ្រងសំណុំរឿងក្នុងការរៀបចំផែនការសម្រាប់សេវាកម្ម និងកម្មវិធីឧបត្ថម្ភ ឲ្យស្របទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ដែលមានពិការភាពពីកំណើតឬពីក្មេងវ័យ។

រដ្ឋសភាត្រូវតែអនុម័តថវិកា និងជំនួយផ្សេងៗដើម្បីទ្រទ្រង់សេវាកម្ម ជូនប្រជាពលរដ្ឋ ដែលមានពិការភាពពីកំណើតឬពីក្មេងវ័យ។ នៅពេលណាការវាយតម្លៃមើលអំពីតម្រូវការរបស់ប្រជាពលរដ្ឋទាំងនេះ ត្រូវបានធ្វើដោយប្រើខ្នាតរង្វាស់វាយតម្លៃតែមួយដូចៗគ្នាហើយ នោះរដ្ឋសភា និងមន្ត្រីអ្នកអនុមតិច្បាប់ដទៃទៀត ទំនងជានឹងយល់ថា ពត៌មាននេះអាចឲ្យពួកគេជឿទុកចិត្តបាន ហើយមានប្រយោជន៍ សម្រាប់ប្រើប្រាស់ជំនួយដល់ដំណើរការអនុមតិសេចក្តីសម្រេចចិត្តរបស់ពួកគេ។

### តើកម្មវិធីវាយតម្លៃ DDA ជួយប្រជាពលរដ្ឋ ដែលមានពិការភាពពីកំណើតឬពីក្មេងវ័យយ៉ាងដូចម្តេច?

កម្មវិធីវាយតម្លៃ DDA គឺវាស់ស្ទង់មើលអំពីតម្រូវការឧបត្ថម្ភរបស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងការចូលរួមសកម្មភាពផ្សេងៗ។ បន្ថែមលើនេះទៅទៀត កម្មវិធីនេះវាស់ស្ទង់មើលអំពីតម្រូការឧបត្ថម្ភលើឥរិយាបថ, ការប្រកបការងារ, សេវាថែទាំសុខភាព, និងតម្រូការផ្នែកអ្នកលើមើលថែទាំរបស់ប្រជាពលរដ្ឋម្នាក់ៗ។ កម្មវិធីវាយតម្លៃ DDA កំណត់កម្មវិធី និងសេវាកម្ម ដែលប្រជាពលរដ្ឋម្នាក់ៗមានលក្ខណសម្បត្តិទទួល និងទំហំបរិមាណនៃសេវាកម្ម ដែលពួកគេអាចត្រូវបានអនុញ្ញាតឲ្យទទួល។

### តើនរណាត្រូវចូលរួមក្នុងកម្មវិធីវាយតម្លៃ DDA?

នាយកគ្រប់គ្រងសំណុំរឿង (Case Manager) នឹងទៅជួបប្រជាពលរដ្ឋ ដែលមានពិភាពពីកំណើតឬក្មេងវ័យដោយផ្ទាល់ ដោយរួមអមដំណើរយ៉ាងតិចណាស់ដោយមនុស្សម្នាក់ ដែលស្គាល់អតិថិជនច្បាស់លាស់។ អ្នកតំណាងស្របច្បាប់ត្រូវបានអញ្ជើញ ឲ្យចូលរួមជានិច្ច។

### តើកម្មវិធីវាយតម្លៃនេះនឹងត្រូវប្រើពេលយូរប៉ុណ្ណា?

ជាធម្មតា បទសម្ភាសនៃការវាយតម្លៃនេះប្រើពេលប្រហែលពី 2 ទៅ 4 ម៉ោង អាស្រ័យតាមកត្តាមួយចំនួន។ ជាឧទាហរណ៍ ការវាយតម្លៃលើកដំបូងប្រើពេលយូរជាងការវាយតម្លៃសាឡើងវិញ។ បើពលរដ្ឋម្នាក់នោះត្រូវការសេវាថែទាំសុខភាពផ្ទាល់ខ្លួនខាងផ្នែកកម្មវិធី Medicaid (មេឌីខេដ) ផងនោះ នោះការវាយតម្លៃនេះរឹតតែត្រូវប្រើពេលយូរបន្តិច។

### តើកម្មវិធីវាយតម្លៃ DDA ត្រូវធ្វើឡើងញឹកញាប់ប៉ុណ្ណា?

ប្រជាពលរដ្ឋដែលទទួលសេវាកម្មបង់ថ្លៃនឹងត្រូវទទួលកម្មវិធីវាយតម្លៃនេះយ៉ាងតិចណាស់មួយឆ្នាំម្តង។ បើតម្រូវការរបស់ពលរដ្ឋរូបនោះមានការប្រែប្រួលនៅក្នុងអំឡុងពេលនៃឆ្នាំកំណត់ នោះអតិថិជនប្រហែលជាអាចនឹងត្រូវការការវាយតម្លៃណាមួយជាបន្ថែម។

### បើមានអតិថិជនណាម្នាក់មិនចង់ទទួលការវាយតម្លៃ នោះតើនឹងមានការអ្វីកើតឡើងដល់អតិថិជនរូបនោះ?

បើមានអតិថិជនណាម្នាក់មិនចង់ទទួលការវាយតម្លៃ DDA ទេ ហើយអតិថិជនរូបនោះរស់នៅក្នុងសហគមន៍នេះ នោះនាយកដ្ឋានពិបាកនឹងដឹងថាតើគាត់ត្រូវការសេវាឧបត្ថម្ភប្រភេទណាណាស់។ អតិថិជនរូបនោះអាចបដិសេធ មិនទទួលយកនូវការវាយតម្លៃណាមួយបាន ក៏ប៉ុន្តែនាយកដ្ឋាន DDA មិនអាចអនុញ្ញាតឲ្យអតិថិជនរូបនោះទទួលសេវាកម្មណាមួយ ដោយគ្មានការវាយតម្លៃ DDA បានឡើយ។

## តើកម្មវិធីវាយតម្លៃ DDA មានអ្វីខ្លះ?

ការវាយតម្លៃ DDA មានបីផ្នែក ឬបីបែបបទ (Modules) ៖

### 1. ផ្នែកវាយតម្លៃមើលការឧបត្ថម្ភ

ផ្នែកវាយតម្លៃមើលការឧបត្ថម្ភ (Support Assessment Module) រួមមានខ្នាតប្រពលភាពឧបត្ថម្ភ (Supports Intensity Scale, SIS) សម្រាប់អតិថិជនទាំងអស់ ចាប់ពីអាយុ 16 ឆ្នាំឡើងទៅ។ SIS គឺជារង្វាស់វាយតម្លៃ ដែលបានត្រូវទទួលស្គាល់កម្រិតថ្នាក់ជាតិ ហើយបានត្រូវប្រើប្រាស់នៅក្នុងរដ្ឋជាច្រើន ដើម្បីវាស់ស្ទង់មើលតម្រូវការឧបត្ថម្ភ សម្រាប់ប្រជាពលរដ្ឋ ដែលមានពិការភាព។ សូមចូលមើលគេហទំព័រ www.siswebsite.org/index.ww ដើម្បីស្វែងយល់ពត៌មានបន្ថែមអំពី SIS។

សម្រាប់កុមារអាយុក្រោម 16 ឆ្នាំ គេនឹងប្រើកម្រងសំណួរប្រមាណម្លៃសំណួរ ដើម្បីវាស់ស្ទង់មើលតម្រូវការឧបត្ថម្ភរបស់ពួកគេ។ ផ្នែកវាយតម្លៃមើលការឧបត្ថម្ភក៏រួមមាននូវការវាយតម្លៃមើលអំពីតម្រូវការអ្នកមើលថែទាំ, បញ្ហាឥរិយាបថ, និងការមើលគ្រប់គ្រងការពារផងដែរ។

### 2. ផ្នែកវាយតម្លៃមើលកម្រិតសេវាកម្ម

ផ្នែកវាយតម្លៃមើលកម្រិតសេវាកម្ម (Service Level Assessment Module) បានត្រូវប្រើប្រាស់ ដើម្បីវាយតម្លៃមើលការឧបត្ថម្ភ ដែលអតិថិជនត្រូវការ ដើម្បីទ្រទ្រង់សកម្មភាពរស់នៅ និងការថែទាំផ្ទាល់ខ្លួនប្រចាំថ្ងៃ។ ចម្លើយទៅនឹងសំណួរទាំងនេះជួយនាយកគ្រប់គ្រងសំណុំរឿងក្នុងការកំណត់មើលសេវាថែទាំផ្ទាល់ខ្លួន ដែលអតិថិជនរូបនោះនឹងទទួលបាន។

### 3. ផែនការឧបត្ថម្ភឯកត្តជន

ផែនការឧបត្ថម្ភឯកត្តជន (Individual Support Plan, ISP) រៀបរាប់អំពីការឧបត្ថម្ភ ដែលគេនឹងផ្តល់ជូន ដើម្បីជួយបំពេញតម្រូវការរបស់អតិថិជន។ ISP រៀបរាប់យ៉ាងល្អិតល្អន់អំពីកម្រិតបរិមាណសេវាបង់ថ្លៃ ដែលអតិថិជនមានលក្ខណសម្បត្តិអាចនឹងទទួលបាន និងថាតើនរណានឹងផ្តល់សេវានោះ។ ផែនការនេះក៏នឹងរៃករកមុខសញ្ញានៃការឧបត្ថម្ភ ដែលអតិថិជនមាន ដែលរដ្ឋមិនបានបង់ថ្លៃជូនផងដែរ។ ផែនការនេះនឹងត្រូវគេបោះពុម្ព ហើយប្រគល់ជូនអតិថិជន នៅក្រោយវគ្គវាយតម្លៃ និងវគ្គរៀបចំផែនការ។

## តើកម្មវិធីវាយតម្លៃ DDA កំណត់មើល ថាតើអតិថិជនមួយរូបៗមានលក្ខណសម្បត្តិទទួលជំនួយបាន យ៉ាងដូចម្តេច?

ចម្លើយទៅនឹងសំណួរទាំងក្នុងផ្នែកវាយតម្លៃមើលការឧបត្ថម្ភ និងផ្នែកវាយតម្លៃមើលកម្រិតសេវាកម្ម នឹងបង្កើតបានអ្វីដែលហៅថា "ពិន្ទុស្រួចស្រាវ" ("acuity scores")។ ពិន្ទុស្រួចស្រាវគឺជារង្វាស់អំពីប្រពលភាពនៃតម្រូវការឧបត្ថម្ភរបស់អតិថិជន ប្រៀបធៀបទៅបុគ្គលដទៃៗទៀត ដែលត្រូវបានទទួលការវាយតម្លៃដែរ។ ពិន្ទុស្រួចស្រាវរបស់អតិថិជន ដែលចេញពីការវាយតម្លៃរបស់ពួកគេជួយកំណត់មើលអំពីលក្ខណសម្បត្តិ ទទួលកម្មវិធី និងសេវាកម្មនានា ដូចជា ៖

- សេវាថែទាំផ្ទាល់ខ្លួន
- សេវាផ្អែកលើលំនៅដ្ឋាន និងសហគមន៍ *DDA*
- សេវាជំនួយជំនួសម្តងម្កាល
- សេវាបុគ្គល និងគ្រួសារ
- សេវាបម្រើអតិថិជនតាមលំនៅដ្ឋានឯកជន
- កម្មវិធីសិទ្ធិបម្រើការងារ ឬសហគមន៍

## ចុះបើមាននរណាម្នាក់ពុំយល់ស្របតាមលទ្ធផលនៃការវាយតម្លៃ DDA?

បើមាននរណាម្នាក់ពុំយល់ស្របតាមលទ្ធផលនៃការវាយតម្លៃ DDA នោះគេអាចស្នើសុំឧទ្ធរណ៍បាន។ នៅក្នុងពេលប្រជុំវាយតម្លៃ នាយកគ្រប់គ្រងសំណុំរឿងនឹងផ្តល់ពត៌មានស្តីពីសិទ្ធិស្នើសុំឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ក្រសួង ដែលយោលលើការវាយតម្លៃ DDA។

**ចុះបើខ្ញុំមានសំណួរបន្ថែមទៀត?**

*សូមទូរស័ព្ទទាក់ទងនាយកគ្រប់គ្រងសំណុំរឿង ឬសូមចូលមើលគេហទំព័រកម្មវិធីវាយតម្លៃ DDA តាមអាសយដ្ឋាន ៖*
**www.dshs.wa.gov/ddd/CAP.shtml**